# យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិករបស់សាធារណរដ្ឋកូរ៉េ

សម្រាប់កូរ៉េខាងត្បូង ឥណ្ឌូប៉ាស៊ីហ្វិក ក្រៅពីជាតំបន់ដែលប្រកបដោយសក្តានុពលសេដ្ឋកិច្ច និងយុទ្ធសាស្ត្រនយោបាយការទូតដ៏ចម្បង តំបន់នេះក៏ជាបណ្តុំនៃដៃគូឧស្សាហកម្មយុទ្ធសាស្ត្រដូចជា គ្រឿងអេឡិចត្រូនិកជាដើម។ ជាមួយគ្នានោះ តំបន់នេះក៏ត្រូវបានហ៊ុមព័ទ្ធដោយបញ្ហាប្រឈមនានា ដែលគំរាមកំហែងដល់សន្តិភាព សេរីភាព និងវិបុលភាព និងសណ្តាប់ធ្នាប់ដែលយកច្បាប់អន្តរជាតិជា មូលដ្ឋាន។ បញ្ហាប្រឈមដែលកើតនៅក្នុងតំបន់នេះ មានរាប់ចាប់ពីការប្រកួតប្រជែងឥទ្ធិពល ការរត់ ប្រណាំងសព្វាវុធនៃបណ្តាប្រទេសធំៗក្នុងតំបន់ កង្វះយន្តការជំរុញការកសាងតម្លាភាព និងការបង្កើន ជំនឿទុកចិត្តខាងយោធា និងសន្តិសុខ ការកសាងសមត្ថភាពនុយក្លេអ៊ែរ និងមីស៊ីលអន្តរទ្វីបរបស់កូរ៉េ ខាងជើង សេរីភាពខាងនាវាចរណ៍ ដែលបង្កការរំខាននៅក្នុងបណ្តាញខ្សែចង្វាក់ផ្គត់ផ្គង់ជាដើម។ ជាមួយនឹងការប្រណាំងប្រជែងគ្នាយ៉ាងខ្លាំងរវាងមហាអំណាចចិន និងសហរដ្ឋអាម៉េរិកដែលបានដាក់ ចេញនូវគម្រោង និងយុទ្ធសាស្ត្រដែលមានលក្ខណៈប្រឈមគ្នាយ៉ាងចាក់ស្រែះដូចជា គម្រោង ខ្សែក្រវ៉ាត់និងផ្លូវ (BRI) ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (RCEP) កិច្ចសន្ទនាសន្តិសុខចតុភាគី (QUAD) សម្ព័ន្ធភាព AUKUS និងយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិក ជាដើម។ ក្នុងបរិបទនេះ មហាអំណាច ពិភពលោក បានព្យាយាមកៀងគរប្រទេសជាដៃគូទាំងនៅក្នុងនិងក្រៅតំបន់ដើម្បីជំរុញពង្រឹងកិច្ចសហ ប្រតិបត្តិការ និងសាមគ្គីភាព ដើម្បីបង្ហាញនូវសាច់ដុំសេដ្ឋកិច្ច សម្ព័ន្ធភាព ក៏ដូចជាសាច់ដុំយោធាដោយ ប្រយោល ព្រមទាំងធ្វើការគូសបង្ហាញទៅដៃគូរបស់ខ្លួននៅគ្រប់ទិដ្ឋភាព និងគ្រប់លទ្ធភាពដែលខ្លួន មាន ក្នុងគោលដៅធ្វើយ៉ាងណា រាំងខ្ទប់នូវការរីកសាយភាយឥទ្ធិពលរបស់គូបដិបក្ខរបស់ខ្លួន។

ប្រធានាធិបតីសាធារណរដ្ឋកូរ៉េ លោក យូន សុក-យ៉ូល (Yoon Suk-yeol) បានធ្វើសេចក្តី ប្រកាសកាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងកិច្ចប្រជុំកំពូលសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អា ស៊ាន) ដែលធ្វើឡើងនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា និងក្រោយមកបានគូសបញ្ជាក់ជាថ្មី ទៀតនៅខាងក្រៅកិច្ចប្រជុំក្រុមប្រទេសឧស្សាហកម្មលូតលាស់ទាំង២០ (G-20) នៅកោះបាលី ប្រទេសឥណ្ឌូណេស៊ី។ ការប្រកាសនេះគឺជាការឆ្លើយតបជាផ្លូវការរបស់សាធារណរដ្ឋកូរ៉េ ចំពោះគោល នយោបាយឥណ្ឌូប៉ាស៊ីហ្វិករបស់សហរដ្ឋអាម៉េរិក ដែលជាសម្ព័ន្ធមិត្តមិនអាចខ្វះបានរបស់ខ្លួន និងក្នុង នាមសាធារណរដ្ឋកូរ៉េដែលជាមហាអំណាចកណ្តាល ក៏ដូចជាជានាគសេដ្ឋកិច្ចមួយនៅតំបន់អាស៊ីផង ដែរ។

នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ សាធារណរដ្ឋកូរ៉េបានប្រកាសព័ត៌មានលម្អិតអំពីយុទ្ធសាស្ត្រ ឥណ្ឌូប៉ាស៊ីហ្វិកដោយផ្តោតសំខាន់លើការជំរុញសេរីភាព សន្តិភាព និងវិបុលភាព តាមរយៈការបង្កើត សណ្តាប់ធ្នាប់ដោយផ្អែកលើច្បាប់ និងកិច្ចសហប្រតិបត្តិការស្តីពីសិទ្ធិមនុស្ស។ របាយការណ៍នេះបាន គូសបញ្ជាក់ថា រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េនឹងប្រកាន់ខ្ជាប់គោលការណ៍ស្នូលចំនួន៩ ដើម្បីសម្រេចឱ្យ

បាននូវចក្ខុវិស័យអំពីតំបន់ឥណ្ឌូប៉ាស៊ីហ្វិកសេរី សន្តិភាព និងវិបុលភាព ដោយផ្អែកទៅលើគោលការណ៍ចំនួនបីនៃកិច្ចសហប្រតិបត្តិ៖ "គ្របដណ្តប់ ជឿទុកចិត្ត និងផ្តល់ឱ្យគ្នាទៅវិញទៅមក"។ ការប្រកាសនេះ ត្រូវបានទទួលការសាទរយ៉ាងពេញទំហឹងពីសហរដ្ឋអាម៉េរិកជាសម្ព័ន្ធមិត្ត ជាមួយគ្នានោះនៅក្នុងសេចក្តីប្រកាសព័ត៌មានមួយរបស់ទីប្រឹក្សាសន្តិសុខជាតិអាម៉េរិកបានគូសបញ្ជាក់ថា យុទ្ធសាស្ត្រនេះបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ប្រធានាធិបតីសាធារណរដ្ឋកូរ៉េលោក យូន សុក-យ៉ូល (Yoon Suk-yeol) ក្នុងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយសម្ព័ន្ធមិត្ត និងដៃគូក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក បង្កើនសមត្ថភាពរួមជាមួយសហរដ្ឋអាម៉េរិក ដើម្បីពង្រឹងសន្តិភាព និងសន្តិសុខអន្តរជាតិ ក៏ដូចជាជំរុញការមិនរីកសាយភាយអាវុធនុយក្លេអ៊ែរ។

ជាការពិតណាស់ គោលនយោបាយរបស់សាធារណរដ្ឋកូរ៉េក្រោមការដឹកនាំរបស់លោក យូន សុក-យ៉ូល (Yoon Suk-yeol) គឺការប្រកាន់យកយ៉ាងជាក់លាក់ដោយផ្តោតសំខាន់លើ "*សេរីភាព*" និង "*សណ្តាប់ធ្នាប់អន្តរជាតិដោយផ្អែកលើតម្លៃសកល*" ដោយប្រធានាធិបតីកូរ៉េបានអំពាវនាវឱ្យមាន "*ការកសាងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកដោយសេរី សន្តិភាព និងវិបុលភាព តាមរយៈកិច្ចសហប្រតិបត្តិការជាមួយប្រទេសសំខាន់ៗ រួមទាំងសមាគមអាស៊ានផងដែរ*"។ បើគេពិនិត្យលើខ្លឹមសារនេះ វាមានអត្ថន័យស្រដៀងគ្នាទៅនឹងគោលការណ៍របស់សហរដ្ឋអាម៉េរិកដែលលើកឡើងអំពី "*ឥណ្ឌូប៉ាស៊ីហ្វិក សេរី បើកចំហ និងវិបុលភាព*" ជាសម្ព័ន្ធមិត្តដ៏ចម្បងក្នុងវិស័យសន្តិសុខរបស់កូរ៉េខាងត្បូងផងដែរ។ វាគឺជាសារមួយដែលកូរ៉េខាងត្បូងផ្តល់នូវចម្លើយដ៏ពេញចិត្តទៅកាន់សហរដ្ឋអាម៉េរិក អំពីឆន្ទៈនិងការគាំទ្ររបស់កូរ៉េខាងត្បូង ក្នុងនាមជាសម្ព័ន្ធមិត្ត និងជាប្រទេសមានទម្ងន់យុទ្ធសាស្ត្រនៅក្នុងតំបន់។

គួរបញ្ជាក់ថា នៅចំពោះមុខយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិករបស់សហរដ្ឋអាម៉េរិក ដែលត្រូវបានគេមើលឃើញថា មានគោលដៅសំខាន់ផ្តោតទៅលើការរីកចម្រើនយ៉ាងលឿនរហ័សរបស់មហាអំណាចចិន ច្បាស់ណាស់ដែលថាកូរ៉េខាងត្បូងពិតជាមិនចង់យកខ្លួនទៅប្រឈមដោយផ្ទាល់ជាមួយនឹងចិន ដែលជាដៃគូពាណិជ្ជកម្មធំជាងគេរបស់ខ្លួននោះឡើយ ដោយសារទំហំពាណិជ្ជកម្មកូរ៉េខាងត្បូង-ចិន តំណាងឱ្យរហូតដល់ទៅ៣០%នៃទំហំពាណិជ្ជកម្មសរុបរបស់កូរ៉េខាងត្បូងឯណោះ។ នៅក្នុងយុទ្ធសាស្ត្រនេះ កូរ៉េខាងត្បូងបានគូសបញ្ជាក់ថា ខ្លួនរីករាយនឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយរាល់បណ្តាប្រទេសទាំងអស់ដោយមិនចំពោះ ដោយគោរពទៅតាមចក្ខុវិស័យ គោលដៅ និងគោលការណ៍ដូចដែលបានថែងខាងលើ។ ទោះជាយ៉ាងណា គេបានដឹងរួចហើយថា បញ្ហាដ៏រសើបដែលកូរ៉េខាងត្បូងយកចិត្តទុកដាក់ខ្លាំងបំផុតនោះគឺស្ថិរភាពនៅឧបទ្វីបកូរ៉េ ពោលគឺសកម្មភាពអភិវឌ្ឍអាវុធនុយក្លេអ៊ែរ និងការបាញ់មីស៊ីលជាបន្តបន្ទាប់របស់កូរ៉េខាងជើងដែលមានចិនជាខ្នងបង្អែក ដែលបានបង្កឱ្យមានការព្រួយបារម្ភជាខ្លាំងអំពីស្ថិរភាព និងសន្តិសុខនៅលើឧបទ្វីបនេះ ក៏ដូចជាតំបន់អាស៊ីបូព៌ាទាំងមូល ហើយសហរដ្ឋអាម៉េរិកគឺជាសម្ព័ន្ធមិត្តដ៏សំខាន់ និងអាចពឹងពាក់បានរបស់កូរ៉េខាងត្បូងនៅចំពោះមុខ។ ហេតុនេះហើយ អ្វីដែលកូរ៉េខាងត្បូងសង្កត់ធ្ងន់អំពីការប្រកាន់ខ្ជាប់របស់ខ្លួននោះគឺ សេរីភាព សន្តិភាព

និងវិបុលភាព ជាមួយសណ្តាប់ធ្នាប់ដែលមានតម្លៃជាសកល។ ជាមួយគ្នានេះ សកម្មភាពដ៏គួរឱ្យព្រួយបារម្ភរបស់មហាអំណាចចិន ដែលបាននិងកំពុងតែពង្រីកនិងពង្រឹងមូលដ្ឋានរបស់ខ្លួននៅលើបណ្តាកោះសិប្បនិម្មិតក្នុងដែនសមុទ្រចិនខាងត្បូង បានបង្កហានិភ័យជាខ្លាំងទៅលើស្ថិរភាព និងសន្តិសុខ ព្រមទាំងសេរីភាពនាវាចរណ៍ក្នុងតំបន់ដែលជាចំណុចស្នូលសំខាន់នៃឥណ្ឌូប៉ាស៊ីហ្វិក ទាំងក្នុងវិស័យសេដ្ឋកិច្ច និងយុទ្ធភូមិសាស្ត្រនយោបាយ។ ហេតុនេះហើយ បើទោះបីជាកូរ៉េខាងត្បូងមិនអាចចេញមុខបរិហារចំៗក្តី ក៏ប៉ុន្តែមហាអំណាចតំបន់មួយនេះ ក៏ត្រូវតែបង្ហាញជំហររបស់ខ្លួនឱ្យបានជាក់លាក់ និងប្រកបដោយការប្រុងប្រយ័ត្នទៅលើការវិវត្តស្ថានការណ៍នៅក្នុងតំបន់ផងដែរ។

លើសពីនេះទៅទៀត បើងាកទៅមើលសង្គ្រាមរបស់រុស្ស៊ីនៅអ៊ុយក្រែន ដែលបានបង្កឱ្យពិភពលោកទាំងមូលជួបប្រទះនឹងវិបត្តិថាមពល សេដ្ឋកិច្ច និងស្បៀងអាហារ ហើយមកដល់ពេលនេះ គេមិនអាចដាក់ទណ្ឌកម្មធ្ងន់ធ្ងរណាមួយឱ្យមានប្រសិទ្ធភាព ដើម្បីបញ្ឈប់សកម្មភាពឈ្លានពានរបស់មហាអំណាចយោធាទីពីរលើពិភពលោកនេះឡើយ។ បើទោះបីជាមានការវាយតម្លៃ និងសន្និដ្ឋាន ពីសំណាក់អ្នកសិក្សាស្រាវជ្រាវ និងអ្នកយុទ្ធសាស្ត្រជាច្រើនថា ចិននឹងមិនអាចយកបទពិសោធការឈ្លានពានរបស់រុស្ស៊ីទៅលើអ៊ុយក្រែនមកអនុវត្តដូចគ្នានៅក្នុងករណីសំណុំរឿងតៃវ៉ាន់ក្តី តែបើគេពិនិត្យមើលជំហររបស់ចិននៅក្នុងសំណុំរឿងអ៊ុយក្រែន ការខិតរកគ្នាកាន់តែខ្លាំងរវាងចិននិងរុស្ស៊ីនៅក្នុងការប្រឈមជាមួយសហរដ្ឋអាម៉េរិកក៏ដូចជាបស្ចិមប្រទេស ស្របពេលដែលស្ថានការណ៍នៅច្រកសមុទ្រតៃវ៉ាន់កាន់តែតានតឹងខ្លាំងឡើងៗ សុទ្ធសឹងតែជាហេតុផលដែលនាំឱ្យពិភពលោកបាននិងកំពុងតាមដានយ៉ាងយកចិត្តដាក់ ដែលធ្វើឱ្យមានការព្រួយបារម្ភជាខ្លាំងអំពីលទ្ធភាពដែលចិនអាចប្រើប្រាស់កម្លាំងដើម្បីបង្រួបបង្រួមយកកោះតៃវ៉ាន់។ កូរ៉េខាងត្បូងដែលជាប្រទេសនៅក្បែរខាងចិនផងនោះ ពិតជាយល់យ៉ាងជាក់ច្បាស់ថា ប្រសិនបើសង្គ្រាមនៅច្រកសមុទ្រតៃវ៉ាន់ផ្ទុះឡើងក្នុងករណីនឹកស្មានមិនដល់ណាមួយពិតមែន វានឹងរាលដាលទៅជាសង្គ្រាមរវាងមហាអំណាច ដែលបង្កជាមហន្តរាយនឹកស្មានមិនដល់ជាក់ជាមិនខាន ព្រោះសហរដ្ឋអាម៉េរិក និងជប៉ុន អាចនឹងលូកដៃចូលដោយមិនឈរឱបដៃឈរមើលចិនលេបយកកោះតៃវ៉ាន់ដោយងាយៗនោះឡើយ ហើយក្រោយពីការចូលអន្តរាគមន៍ពីសំណាក់សហរដ្ឋអាម៉េរិក និងជប៉ុនទៅក្នុងសង្គ្រាមនេះ កូរ៉េខាងជើង និងរុស្ស៊ី ច្បាស់ជានឹងមិនបណ្តែតបណ្តោយឱ្យសហរដ្ឋអាម៉េរិកចាត់ចែងទៅលើសង្គ្រាម ដែលកំពុងតែឆាមឆេះនៅក្បែរផ្ទះរបស់ខ្លួនជាក់ជាមិនខានឡើយ។ នេះគឺជាករណីដែលកូរ៉េខាងត្បូងខ្លួនឯងផ្ទាល់ មិនប្រាថ្នាឱ្យកើតមានឡើងនោះឡើយ។ ដូច្នេះហើយ មេដឹកនាំសាធារណរដ្ឋកូរ៉េទំនងជាយល់យ៉ាងច្បាស់ថា ការជំរុញឱ្យបណ្តាប្រទេសក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិករក្សាស្ថានភាពដើមនៅក្នុងតំបន់ និងគោរពគោលការណ៍សន្តិភាព សេរីភាព ព្រមទាំងគោរពច្បាប់អន្តរជាតិ គឺជាចំណុចស្នូលសំខាន់ដែលសាធារណរដ្ឋកូរ៉េត្រូវកំណត់នៅក្នុងនយោបាយការបរទេសរបស់ខ្លួន។

សរុបមក សាធារណរដ្ឋកូរ៉េកំពុងបន្តព្យាយាមថ្លឹងថ្លែងឱ្យមានតុល្យភាពរវាងមហាអំណាចចិន ដែលជាដៃគូពាណិជ្ជកម្មដ៏ធំ និងសហរដ្ឋអាម៉េរិកដែលជាសម្ព័ន្ធមិត្តសន្តិសុខដ៏ចម្បងរបស់ខ្លួន។ ការដាក់ចេញនូវយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកនេះ គឺជាមគ្គុទ្ទេសក៍មួយសម្រាប់ការអនុវត្តគោលនយោបាយការបរទេសរបស់សាធារណរដ្ឋកូរ៉េនៅក្នុងទំនាក់ទំនងរបស់ខ្លួន ទាំងជាមួយមហាអំណាចសហរដ្ឋអាម៉េរិក មហាអំណាចចិន និងបណ្តាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកទាំងមូល ដោយបានគូសបញ្ជាក់ថា កូរ៉េខាងត្បូងនៅតែប្រកាន់ជំហរធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តារដ្ឋនានា និងអង្គការក្នុងតំបន់ដើម្បីផលប្រយោជន៍ និងការរីកចម្រើនសេដ្ឋកិច្ចជាមួយគ្នា ហើយដែលត្រូវតែធ្វើឡើងប្រកបដោយបរិយាកាសសេរី សន្តិភាព និងដោយផ្អែកលើច្បាប់អន្តរជាតិ ដោយខ្លួនមិនគាំទ្រឡើយនូវការប្រើប្រាស់កម្លាំងដើម្បីផ្លាស់ប្តូរស្ថានភាពដែលកំពុងមាននាពេលបច្ចុប្បន្ននៅក្នុងតំបន់។ នៅក្នុងយុទ្ធសាស្ត្រនេះក៏បានគូសបញ្ជាក់ផងដែរថា ដើម្បីធានាបាននូវសមាហរណកម្ម យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិករបស់កូរ៉េខាងត្បូងបានចែងដោយប្រយោលថា "*យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិករបស់យើង រួមបញ្ចូលទាំងគោលដៅ និងមិនរាប់បញ្ចូលប្រទេសជាក់លាក់ណាមួយឡើយ។ យើងនឹងធ្វើការជាមួយគ្រប់ដៃគូដែលស្របតាមចក្ខុវិស័យ និងគោលការណ៍នៃកិច្ចសហប្រតិបត្តិការរបស់យើង។ យើងនឹងនៅតែបើកចំហសម្រាប់ប្រទេសទាំងក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក និងក្រៅតំបន់*"៕